ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ......០៦០......អ.ស.ហ.ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីបរធនបាលកិច្ច
- បានទទួលការឯកភាពពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងសម័យប្រជុំ នាថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីយន្តការនិងនីតិវិធីនៃការផ្សះផ្សា និងការដោះស្រាយវិវាទដោយក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ច (**ក.ដ.ប.**) ពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច និងការផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច ប្រកបដោយប្រសិទ្ធភាព និងសមធម៌ ក្នុងគោលដៅការពារវិនិយោគិន ភាគីបរធនបាលកិច្ច ព្រមទាំងបុគ្គលចូលរួមដទៃទៀតក្នុងវិស័យបរធនបាលកិច្ច។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ចរបស់បរធនបាល ប្រតិបត្តិករបរធនបាល និងការផ្តល់សេវាបរធនបាលកិច្ចរបស់អ្នកចូលរួមដទៃទៀតក្នុងវិស័យបរធនបាលកិច្ច ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី/ការទទួលស្គាល់ពីនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**)។

**ប្រការ៣.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីបរធនបាលកិច្ច៖

- **ពាក្យបណ្តឹង** សំដៅដល់ពាក្យស្នើសុំការផ្សះផ្សា ឬពាក្យបណ្តឹងសុំការដោះស្រាយវិវាទ អនុលោមតាមប្រកាសនេះ។
- **បណ្តឹងរដ្ឋបាល** សំដៅដល់បណ្តឹងរបស់ភាគីវិវាទទៅ **ន.ប.ធ.** តវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ច។
- **បណ្តឹងពាក់ព័ន្ធនឹងវិវាទបរធនបាលកិច្ច** សំដៅដល់បណ្តឹងទាមទារឱ្យមានការផ្សះផ្សា ឬការដោះស្រាយវិវាទពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការ និងការផ្តល់សេវាពាក់ព័ន្ធនឹងបរធនបាលកិច្ច។
- **ភាគីវិវាទ** សំដៅដល់ភាគីវិវាទណាមួយ ឬភាគីវិវាទទាំងសងខាង ដែលកំពុងមានវិវាទ ជម្លោះ ទំនាស់ ឬវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច។



Ch. ۲۷

## ជំពូកទី២
## ការដាក់ពាក្យបណ្ដឹង

**ប្រការ៤.-**

ភាគីវិវាទអាចដាក់ពាក្យបណ្ដឹងសុំការផ្សះផ្សា ឬការដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច តាមទម្រង់កំណត់របស់ **ន.ម.ធ.**។

**ប្រការ៥.-**

ភាគីវិវាទដែលដាក់ពាក្យបណ្ដឹងត្រូវមានសមត្ថភាពដោយខ្លួនឯង ឬដោយអ្នកតំណាងស្របតាមច្បាប់ ដូចមានចែងក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៦.-**

ពាក្យបណ្ដឹងត្រូវបញ្ជាក់ឱ្យបានច្បាស់នូវនិទ្ទេសអប្បបរមា ដូចខាងក្រោម៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋាន របស់ភាគីវិវាទនិងរបស់អ្នកតំណាង ប្រសិនមាន
- កម្មវត្ថុនៃបណ្ដឹង និងខ្លឹមសារនៃការទាមទារ
- អង្គហេតុ និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

មន្ត្រីទទួលពាក្យបណ្ដឹងអាចស្នើឱ្យកែតម្រូវពាក្យបណ្ដឹងនោះក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលពាក្យបណ្ដឹង។

**ប្រការ៧.-**

ពាក្យបណ្ដឹងត្រូវបានបដិសេធ ក្នុងករណីណាមួយ ដូចខាងក្រោម៖

- កម្មវត្ថុនៃបណ្ដឹងមិនពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច ឬការផ្ដល់សេវាពាក់ព័ន្ធនឹងបរធនបាលកិច្ច
- ពាក្យបណ្ដឹងដែលមានព័ត៌មានមិនគ្រប់គ្រាន់ ឬមិនសមស្រប
- ពាក្យបណ្ដឹងដែលអ្នកប្ដឹងគ្មានសមត្ថភាពតាមច្បាប់ ឬមិនមានផលប្រយោជន៍ក្នុងវិវាទ
- ពាក្យបណ្ដឹងដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ
- ពាក្យបណ្ដឹងដែលកំពុង ឬត្រូវបានដោះស្រាយដោយតុលាការ
- សិទ្ធិប្ដឹងត្រូវបានរលត់ ក្រោយ ៣ (បី) ខែ បន្ទាប់ពីបញ្ចប់ការជម្រះបញ្ជីបរធនបាលកិច្ច។

**ន.ម.ធ.** ត្រូវជូនដំណឹងអំពីការបដិសេធលើពាក្យបណ្ដឹងនេះទៅអ្នកដាក់ពាក្យបណ្ដឹង ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។

## ជំពូកទី៣
## ភាគីវិវាទ

**ប្រការ៨.-**

ភាគីវិវាទមានសិទ្ធិ ដូចខាងក្រោម៖

- រៀបរាប់អង្គហេតុ និងដាក់បន្ថែមឯកសារសំខាន់នានា



Am CSK

- លើកសំណូមពរ និងយោបល់ផ្សេងៗក្នុងដំណើរការនីតិវិធី
- ស្នើសុំដាក់បញ្ចូលអ្នកបកប្រែភាសា ក្នុងករណីចាំបាច់
- ស្នើសុំពន្យារពេលការផ្សះផ្សា ឬការដោះស្រាយវិវាទ ដោយមានបញ្ជាក់មូលហេតុសមស្រប
- ស្នើសុំថតចម្លងកំណត់ហេតុនៃលទ្ធផលផ្សះផ្សា
- ជ្រើសរើសអ្នកតំណាងស្របច្បាប់
- សិទ្ធិផ្សេងទៀតដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ៩.-**

ភាគីវិវាទមានកាតព្វកិច្ច ដូចខាងក្រោម៖

- ចូលរួមក្នុងនីតិវិធីនៃការផ្សះផ្សា ឬដោះស្រាយវិវាទ ដោយមានភាពស្មោះត្រង់ សីលធម៌ និងអាកប្បកិរិយាសមរម្យ ព្រមទាំងអនុវត្តតាមវិធាននៃការផ្សះផ្សា និងការដោះស្រាយវិវាទ
- សហការជាមួយអ្នកផ្សះផ្សា ឬអ្នកដោះស្រាយវិវាទ និងភាគីវិវាទផ្សេងទៀត
- អនុវត្តនូវគ្រប់ចំណុចដែលបានព្រមព្រៀងនៅក្នុងការផ្សះផ្សា ឬការដោះស្រាយវិវាទ
- អនុវត្តយ៉ាងយកចិត្តទុកដាក់នូវខ្លឹមសារ និងលក្ខខណ្ឌនានាដែលបញ្ញត្តនៅក្នុងប្រកាសនេះ។

**ប្រការ១០.-**

អ្នកប្ដឹងទាមទារអាចដកពាក្យបណ្ដឹងរបស់ខ្លួន ឬព្រមព្រៀងជាមួយភាគីវិវាទម្ខាងទៀតដកខ្លួនចេញពីការផ្សះផ្សា និងការដោះស្រាយវិវាទបានគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ **ន.ប.ធ.**។

## ជំពូកទី៤
## ផ្នែកទី១
## អ្នកផ្សះផ្សា

**ប្រការ១១.-**

អ្នកផ្សះផ្សា ជាមន្ត្រីការិយាល័យដោះស្រាយពាក្យបណ្ដឹង នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច ត្រូវជ្រើសរើស និងតែងតាំងដោយអគ្គនាយកនៃ **ន.ប.ធ.**។

**ប្រការ១២.-**

អ្នកផ្សះផ្សាមានសិទ្ធិអំណាច ដូចខាងក្រោម៖

១- រៀបចំកិច្ចប្រជុំផ្សះផ្សា ដោយអាចជួបប្រជុំជាមួយភាគីវិវាទទាំងអស់ ឬជាមួយភាគីវិវាទដាច់ដោយ-ឡែកពីគ្នា

២- ប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិវាទពីភាគីវិវាទ

៣- ស្នើឱ្យមានអ្នកបកប្រែភាសា អ្នកជំនាញ និងបុគ្គលពាក់ព័ន្ធផ្សេងៗទៀត ប្រសិនចាំបាច់

៤- ពន្យារពេលកិច្ចប្រជុំផ្សះផ្សា ដើម្បីអនុញ្ញាតឱ្យភាគីវិវាទអាចពិចារណាលើការស្នើដាក់លាក់ណាមួយ ឬដើម្បីប្រមូលនូវរាល់ព័ត៌មាន ឬគំនិតយោបល់ផ្សេងៗ ក្នុងករណីចាំបាច់

៥- ប្រមូលរាល់ឯកសារ និងព័ត៌មានពាក់ព័ន្ធ ដែលទទួលបានក្នុងដំណើរការផ្សះផ្សា



Ch VK

៦- សិទ្ធិអំណាចផ្សេងទៀតដែលមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

អ្នកផ្សះផ្សាមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

១- សាកសួរភាគីវិវាទដើម្បីស្វែងរកចំណុចវិវាទ

២- កំណត់នូវចំណុចវិវាទ និងពិចារណាពីវិធីសាស្ត្រសម្រាប់ការផ្សះផ្សា

៣- បង្កភាពងាយស្រួលដល់ភាគីវិវាទ ក្នុងការចរចាដោយសន្តិវិធី

៤- បង្កើតជម្រើសផ្សេងៗដែលជាដំណោះស្រាយសម្រាប់ឱ្យភាគីវិវាទពិចារណា ដើម្បីព្រមព្រៀងគ្នា ឬដើម្បីសះជា

៥- លើកទឹកចិត្ត និងជំរុញភាគីវិវាទឈានទៅដល់ការព្រមព្រៀងគ្នាតាមដែលអាចធ្វើទៅបាន

៦- អនុវត្តមុខងារ និងភារកិច្ចដោយត្រឹមត្រូវ ស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងវិធានផ្សះផ្សា

៧-អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀត ដែលមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ១៣.-**

មិនអាចអនុវត្តមុខងារជាអ្នកផ្សះផ្សាបានឡើយ ប្រសិនអ្នកផ្សះផ្សានោះ៖

១- ជា ឬធ្លាប់ជាសហព័ទ្ធនៃភាគីវិវាទ

២- ជាញាតិលោហិតរហូតដល់ថ្នាក់ទី៤ ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី៣ របស់ភាគីវិវាទណាមួយ

៣- ធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីវិវាទ

៤- ជាបុគ្គលដែលមានផលប្រយោជន៍ក្នុងវិវាទ

៥- ធ្លាប់ជាសាក្សី ឬជាអ្នកតំណាង ឬជាអ្នកជំនាញផ្តល់ប្រឹក្សាឱ្យភាគីវិវាទ

៦- ស្ថិតក្នុងស្ថានភាពណាមួយដែលលេចចេញនូវភាពលម្អៀង ឬទំនាស់ផលប្រយោជន៍។

បុគ្គលដែលត្រូវបានចាត់តាំងជាអ្នកផ្សះផ្សា ត្រូវជូនដំណឹងជាបន្ទាន់ទៅ **ន.ម.ឆ.** និងភាគីវិវាទនៅពេលមានភាពជាប់ពាក់ព័ន្ធនឹងស្ថានភាពណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ។ បន្ទាប់ពីទទួលបានដំណឹងអំពីភាពជាប់ពាក់ព័ន្ធនេះ **ន.ម.ឆ.** អាចចាត់តាំងអ្នកផ្សះផ្សាថ្មី។

## ផ្នែកទី២
## អ្នកដោះស្រាយវិវាទ

**ប្រការ១៤.-**

អ្នកដោះស្រាយវិវាទត្រូវជ្រើសរើសដោយ **គ.ជ.ម.**។ អ្នកដោះស្រាយវិវាទអាចជាមន្ត្រីការិយាល័យដោះស្រាយពាក្យបណ្តឹងនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និង/ឬអាចជ្រើសចេញពីមន្ត្រីផ្សះផ្សា និងដោះស្រាយវិវាទពីក្រសួង-ស្ថាប័នពាក់ព័ន្ធ។

**ប្រការ១៥.-**

អ្នកដោះស្រាយវិវាទមានសិទ្ធិអំណាច ដូចខាងក្រោម៖

១- ប្រមូលរាល់ឯកសារ និងព័ត៌មានពាក់ព័ន្ធ ដែលទទួលបានក្នុងដំណើរការផ្សះផ្សា



an 18V

២- ប្រមូលព័ត៌មានពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់

៣- តម្រូវឱ្យមានអ្នកបកប្រែភាសា និងអ្នកជំនាញ ក្នុងករណីចាំបាច់

៤- ស្នើរៀបចំកិច្ចប្រជុំដោះស្រាយវិវាទបរធនបាលកិច្ចទៅ **គ.ដ.ម**.

៥- សិទ្ធិអំណាចផ្សេងទៀតដែលមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

អ្នកដោះស្រាយវិវាទមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

១- ស្នើរៀបចំវេទិកាដោះស្រាយវិវាទទៅ **គ.ដ.ម**.

២- កំណត់នូវចំណុចវិវាទដែលត្រូវដោះស្រាយឱ្យបានច្បាស់លាស់

៣- បង្កភាពងាយស្រួលឱ្យភាគីវិវាទឈានទៅរកការសះជា

៤- អនុវត្តមុខងារ និងភារកិច្ចដោយត្រឹមត្រូវតាមក្រមសីលធម៌វិជ្ជាជីវៈ និងវិធាននៃការដោះស្រាយវិវាទ

៥- រៀបចំសេចក្តីសម្រេចលើវិវាទ ដើម្បីស្នើសុំការពិនិត្យសម្រេចទៅ **គ.ដ.ម**.

៦- អនុវត្តតួនាទី និងភារកិច្ចផ្សេងទៀត ដែលមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ១៦**.-

មិនអាចអនុវត្តមុខងារជាអ្នកដោះស្រាយវិវាទបានឡើយ ប្រសិនអ្នកដោះស្រាយវិវាទនោះ៖

១- ជា ឬធ្លាប់ជាសហព័ទ្ធនៃភាគីវិវាទ

២- ជាញាតិលោហិតរហូតដល់ថ្នាក់ទី៤ ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី៣ របស់ភាគីវិវាទណាមួយ

៣- ធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីវិវាទ

៤- ជាបុគ្គលដែលមានផលប្រយោជន៍ក្នុងវិវាទ

៥- ធ្លាប់ជាសាក្សី ឬជាអ្នកតំណាង ឬជាអ្នកជំនាញផ្តល់ប្រឹក្សាឱ្យភាគីវិវាទ

៦- ស្ថិតក្នុងស្ថានភាពណាមួយដែលលេចចេញនូវភាពលម្អៀង ឬទំនាស់ផលប្រយោជន៍។

**ប្រការ១៧**.-

អ្នកដោះស្រាយវិវាទថ្មីត្រូវជ្រើសរើសក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីកាលបរិច្ឆេទសម្រេចផ្លាស់ប្តូរអ្នកដោះស្រាយវិវាទ ករណីមានការស្នើសុំដកខ្លួនពីអ្នកដោះស្រាយវិវាទ ឬមានការស្នើសុំផ្លាស់ប្តូរអ្នកដោះស្រាយវិវាទពីភាគីវិវាទ ឬមានកាលៈទេសៈណាមួយដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ ឬហេតុការណ៍ណាមួយផ្សេងទៀត ដូចខាងក្រោម៖

១- ការដកខ្លួន ការផ្លាស់ប្តូរ ការបាត់បង់សមត្ថភាព ឬមរណភាពរបស់អ្នកដោះស្រាយវិវាទ លើកលែងករណីអ្នកដោះស្រាយវិវាទមានចំនួនច្រើន ហើយអាចបន្តនីតិវិធីដោះស្រាយវិវាទបាន

២- ករណីប្រធានសក្តិ

៣- ករណីផ្សេងទៀត ដែល **គ.ដ.ម**. យល់ថាប៉ះពាល់ដល់ដំណើរការដោះស្រាយវិវាទ។



ar 16 r

# ជំពូកទី៥
# ការចាប់ផ្តើមនីតិវិធីផ្សះផ្សា និងដោះស្រាយវិវាទ

## ផ្នែកទី១
## នីតិវិធីផ្សះផ្សា

**ប្រការ១៨.-**

អ្នកផ្សះផ្សាត្រូវអញ្ជើញភាគីវិវាទទាំងអស់តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយទំនាក់-ទំនងផ្សេងទៀតតាមការចាំបាច់ ដោយត្រូវបញ្ជាក់អំពីកាលបរិច្ឆេទ ទីកន្លែង និងសមាសភាពចូលរួមកិច្ចប្រជុំផ្សះផ្សាវិវាទ។ ការអញ្ជើញនេះ ត្រូវធ្វើឡើងឱ្យបានយ៉ាងតិច ៥ (ប្រាំ) ថ្ងៃ មុនកាលបរិច្ឆេទនៃកិច្ចប្រជុំផ្សះផ្សាវិវាទ លើកលែងតែមានករណីបន្ទាន់ចាំបាច់ ឬការស្នើសុំរបស់ភាគីវិវាទ។

ប្រសិនភាគីវិវាទមិនបានចូលរួមក្នុងដំណើរការផ្សះផ្សាចំនួន ២ (ពីរ) លើកជាប់ៗគ្នា ដោយគ្មានមូលហេតុសមរម្យ ការផ្សះផ្សានេះអាចចាត់ទុកថាមិនសះជា។ អ្នកផ្សះផ្សាត្រូវរៀបចំជារបាយការណ៍អំពីការមិនសះជា ដាក់ជូន **គ.ជ.ម**. ដើម្បីបន្តនីតិវិធីដោះស្រាយវិវាទ។

**ប្រការ១៩.-**

កិច្ចប្រជុំផ្សះផ្សាត្រូវធ្វើឡើងដោយសម្ងាត់ ហើយមានតែអ្នកផ្សះផ្សានិងភាគីវិវាទប៉ុណ្ណោះ ត្រូវបានអនុញ្ញាតឱ្យមានវត្តមាននៅក្នុងកិច្ចប្រជុំផ្សះផ្សានេះ។

អ្នកបកប្រែភាសា និងអ្នកជំនាញអាចមានវត្តមាននៅក្នុងនីតិវិធីផ្សះផ្សា ប្រសិនអ្នកផ្សះផ្សាយល់ថា អាចជួយដល់ដំណើរការផ្សះផ្សាបាន។ អ្នកបកប្រែ និងអ្នកជំនាញទាំងនោះត្រូវចុះកិច្ចព្រមព្រៀងរក្សាការសម្ងាត់ទៅតាមការកំណត់ដោយ **ន.ម.ធ.**។

អ្នកផ្សះផ្សាអាចជួបប្រជុំជាមួយភាគីវិវាទទាំងអស់ ឬជាមួយភាគីវិវាទដាច់ដោយឡែកពីគ្នា ដោយផ្តល់ពេលវេលាសមស្របដល់ភាគីវិវាទ និងត្រូវធ្វើកំណត់ហេតុ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយអ្នកផ្សះផ្សា និងត្រូវចុះហត្ថលេខា ឬផ្តិតស្នាមមេដៃដោយភាគីវិវាទ។

ការផ្សះផ្សាត្រូវប្រើភាសាខ្មែរ លើកលែងមានការយល់ព្រមប្រើប្រាស់ភាសាផ្សេងដោយអ្នកផ្សះផ្សា។

**ប្រការ២០.-**

នីតិវិធីនៃការផ្សះផ្សាត្រូវផ្អាក ឬបង្អង់ ពេលមានហេតុណាមួយ ដូចខាងក្រោម៖

១- ការដកខ្លួន ការផ្លាស់ប្តូរ ការបាត់បង់សមត្ថភាព ឬមរណភាពរបស់អ្នកផ្សះផ្សា លើកលែងករណីអ្នកផ្សះផ្សាមានចំនួនច្រើន ហើយអាចបន្តនីតិវិធីផ្សះផ្សាបាន

២- ការបាត់បង់សមត្ថភាព ឬមរណភាពរបស់ភាគីវិវាទ

៣- ការរំលត់នីតិបុគ្គលដែលជាភាគីវិវាទ ដោយការរួមបញ្ចូលគ្នា

៤- ករណីប្រធានសក្តិ

៥- ករណីផ្សេងទៀត ដែលអ្នកផ្សះផ្សាយល់ថាប៉ះពាល់ដល់ដំណើរការផ្សះផ្សា។

រយៈពេលនៃការផ្សះផ្សាដូចមានចែងក្នុងប្រការ២២ នៃប្រកាសនេះ ត្រូវផ្អាក ឬបង្អង់រហូតដល់ពេលដែលនីតិវិធីនៃការផ្សះផ្សាត្រូវចាប់ផ្តើមឡើងវិញ។

**ប្រការ២១.-**

ការផ្សះផ្សាត្រូវបញ្ចប់ ក្នុងករណីដូចខាងក្រោម៖

១- ភាគីវិវាទសះជានឹងគ្នា

២- ភាគីវិវាទបានព្រមព្រៀងគ្នាដកខ្លួនចេញពីការផ្សះផ្សា

៣- ភាគីវិវាទដែលប្ដឹងទាមទារបានដកពាក្យបណ្ដឹងវិញ

៤- ភាគីវិវាទដែលប្ដឹងទាមទារទទួលបានដំណឹងអំពីការអញ្ជើញ ប៉ុន្តែមិនចូលរួមក្នុងកិច្ចដំណើរការផ្សះផ្សាវិវាទ

៥- អ្នកផ្សះផ្សា និងភាគីវិវាទ ព្រមព្រៀងគ្នាបញ្ចប់ការផ្សះផ្សា ក្នុងករណីយល់ឃើញថាវិវាទមិនអាចធ្វើការផ្សះផ្សាតទៅទៀតបាន

៦- ភាគីវិវាទបំពានធ្ងន់ធ្ងរចំពោះបញ្ញត្តិនៃប្រកាសនេះ

៧- ភាគីវិវាទបានទទួលមរណភាព ឬបានរំលត់នីតិបុគ្គល ហើយគ្មានអ្នកទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្ដឹង។

**ប្រការ២២.-**

ដំណើរការនៃការផ្សះផ្សាត្រូវបញ្ចប់ក្នុងរយៈពេលយ៉ាងយូរ ៩០ (កៅសិប) ថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលអ្នកផ្សះផ្សាត្រូវបានចាត់តាំងដោយ **ន.ម.ឆ.** លើកលែងករណីដូចខាងក្រោម៖

១- មានហេតុណាមួយដូចបញ្ញត្តក្នុងប្រការ២០ នៃប្រកាសនេះ ឬ

២- មានការសម្រេចរបស់ **ន.ម.ឆ.** តាមការស្នើសុំពន្យារពេលរបស់អ្នកផ្សះផ្សា ឬការស្នើសុំពន្យារពេលតាមការព្រមព្រៀងរបស់ភាគីវិវាទ។

**ប្រការ២៣.-**

ការព្រមព្រៀងរបស់ភាគីវិវាទដែលធ្វើឡើងនៅចំពោះមុខអ្នកផ្សះផ្សា ជាការព្រមព្រៀងដែលមានអានុភាពអនុវត្ត។

ភាគីវិវាទអាចព្រមព្រៀងគ្នារៀបចំកិច្ចព្រមព្រៀងសះជាដាច់ដោយឡែកនៅចំពោះមុខអ្នកផ្សះផ្សា ដោយបញ្ចូលនូវខសន្យា និងលក្ខខណ្ឌផ្សេងៗបន្ថែមទៀតបាន។

**ប្រការ២៤.-**

ចំពោះចំណុចនៃវិវាទដែលភាគីវិវាទមិនបានព្រមព្រៀងគ្នា ត្រូវចាត់ទុកថាមិនសះជា។ អ្នកផ្សះផ្សាត្រូវរៀបចំធ្វើកំណត់ហេតុមិនសះជា ដោយបញ្ជាក់អំពីចំណុចមិនសះជា មូលហេតុ និងព័ត៌មានចាំបាច់ផ្សេងទៀត។ កំណត់ហេតុមិនសះជាត្រូវមានកាលបរិច្ឆេទត្រឹមត្រូវ និងចុះហត្ថលេខាដោយអ្នកផ្សះផ្សា ហើយត្រូវចម្លងជូនគ្រប់ភាគីវិវាទ។

ភាគីវិវាទអាចព្រមព្រៀងបញ្ជូនវិវាទ ឬចំណុចមិនសះជាទៅ **ក.ជ.ម.** ដើម្បីដោះស្រាយតាមនីតិវិធីដូចមានបញ្ញត្តក្នុងផ្នែកទី២ ជំពូកទី៥ នៃប្រកាសនេះ។

## ផ្នែកទី២
## នីតិវិធីដោះស្រាយវិវាទ

**ប្រការ២៥.-**

ការដោះស្រាយវិវាទត្រូវធ្វើឡើងដោយអ្នកដោះស្រាយវិវាទដែលទទួលបានការចាត់តាំងពី **គ.ដ.ម.** ឬដោយក្រុមការងារដោះស្រាយវិវាទដែលទទួលបានការចាត់តាំងពី **គ.ដ.ម.**។

នៅក្នុងការពិនិត្យ និងដោះស្រាយវិវាទ **គ.ដ.ម.** ឬក្រុមការងារដោះស្រាយវិវាទរបស់ **គ.ដ.ម.** ឬអ្នកដោះស្រាយវិវាទ អាចកោះអញ្ជើញភាគីវិវាទ សាក្សី ឬបុគ្គលពាក់ព័ន្ធផ្សេងទៀត ណែនាំឱ្យភាគីវិវាទបញ្ជាក់អំពីការទាមទារ ឬផ្ដល់ព័ត៌មានបន្ថែមលើការទាមទារ ឬស្រាវជ្រាវព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងវិវាទ ដោយយោងតាមការចាំបាច់ ដើម្បីជាមូលដ្ឋានក្នុងការដោះស្រាយវិវាទ។

**ប្រការ២៦.-**

ក្នុងករណី **គ.ដ.ម.** ទទួលយកសំណុំរឿងវិវាទមកដោះស្រាយ **គ.ដ.ម.** ត្រូវ៖

១- ជ្រើសតាំងអ្នកដោះស្រាយវិវាទ ១ (មួយ) រូប ឬច្រើនរូបដែលជាចំនួនសេស តាមការចាំបាច់

២- កំណត់ទីតាំង និងកាលបរិច្ឆេទនៃការដោះស្រាយវិវាទ តាមការស្នើសុំរបស់ភាគីវិវាទ ឬលេខាធិការដ្ឋាន

៣- កំណត់ការចំណាយលើកម្រៃសេវាអ្នកដោះស្រាយវិវាទ

៤- ពិនិត្យការស្នើសុំផ្សេងទៀតរបស់ភាគីវិវាទ ឬលេខាធិការដ្ឋាន។

**ប្រការ២៧.-**

អ្នកដោះស្រាយវិវាទ ឬក្រុមការងារអ្នកដោះស្រាយវិវាទត្រូវចាប់ផ្ដើមនីតិវិធីដោះស្រាយវិវាទ តាមបែបបទ និងនីតិវិធីជាធរមាន និងត្រូវរាយការណ៍ជាប្រចាំពីវឌ្ឍនភាពនៃវិវាទជូន **គ.ដ.ម.**។

**ប្រការ២៨.-**

អ្នកដោះស្រាយវិវាទត្រូវអញ្ជើញភាគីវិវាទទាំងអស់ឱ្យចូលរួមនៅក្នុងវេទិកាដោះស្រាយវិវាទ តាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់ដោយអ្នកដោះស្រាយវិវាទ តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬមធ្យោបាយទំនាក់ទំនងផ្សេងទៀត។ ការអញ្ជើញនេះ ត្រូវធ្វើឡើងឱ្យបានយ៉ាងតិច ៥ (ប្រាំ) ថ្ងៃ មុនកាលបរិច្ឆេទនៃកិច្ចប្រជុំដោះស្រាយវិវាទ លើកលែងតែមានករណីបន្ទាន់ចាំបាច់ ឬការស្នើសុំរបស់ភាគីវិវាទ។

ប្រសិនភាគីវិវាទមិនបានចូលរួមក្នុងដំណើរការដោះស្រាយវិវាទចំនួន ២ (ពីរ) លើកជាប់ៗគ្នា ដោយគ្មានមូលហេតុសមរម្យ ការដោះស្រាយវិវាទនេះអាចចាត់ទុកថាមិនសះជា។ **គ.ដ.ម.** ត្រូវរៀបចំសេចក្ដីសម្រេចបញ្ចប់វិវាទ។

ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ដោយគិតចាប់ពីថ្ងៃចេញសេចក្ដីសម្រេចរបស់ **គ.ដ.ម.** ភាគីវិវាទអាចបន្តនីតិវិធីបណ្ដឹងរដ្ឋបាលទៅអគ្គនាយកនៃ **ន.ម.ធ.** ស្របតាមមាត្រា៣៤ នៃច្បាប់ស្ដីពីបរធនបាលកិច្ច ពុំនោះទេសិទ្ធិប្ដឹងនេះនឹងត្រូវបាត់បង់។ បន្ទាប់ពីរយៈពេល ៣០ (សាមសិប) ថ្ងៃ ដោយគិតចាប់ពីថ្ងៃចេញសេចក្ដីសម្រេចរបស់ **គ.ដ.ម.** ភាគីវិវាទត្រូវអនុវត្តតាមសេចក្ដីសម្រេចរបស់ **គ.ដ.ម.**។ ក្នុងករណីការដោះស្រាយវិវាទមិនសះជា ភាគីវិវាទអាចស្នើសុំបញ្ជូនកំណត់ហេតុមិនសះជាពី **គ.ដ.ម.** ប្ដឹងទៅតុលាការមានសមត្ថកិច្ច។



Ch(/b V

**ប្រការ២៩.-**

វេទិកាដោះស្រាយវិវាទត្រូវធ្វើឡើងដោយសម្ងាត់ ហើយមានតែអ្នកដោះស្រាយវិវាទ និងភាគីវិវាទតែប៉ុណ្ណោះ ត្រូវបានអនុញ្ញាតឱ្យមានវត្តមាននៅក្នុងវេទិកានេះ។

ការដោះស្រាយវិវាទត្រូវប្រើភាសាខ្មែរ លើកលែងតែមានការយល់ព្រមប្រើប្រាស់ភាសាផ្សេងដោយអ្នកដោះស្រាយវិវាទ។

អ្នកបកប្រែភាសា អ្នកជំនាញ មេធាវី សាក្សី និងបុគ្គលពាក់ព័ន្ធផ្សេងទៀត អាចមានវត្តមាននៅក្នុងនីតិវិធីដោះស្រាយវិវាទ ប្រសិនអ្នកដោះស្រាយវិវាទយល់ថាចាំបាច់។ បុគ្គលដែលចូលរួមទាំងអស់នេះត្រូវចុះកិច្ចព្រមព្រៀងរក្សាការសម្ងាត់ ទៅតាមការកំណត់ដោយ **ន.ម.ធ.**។

**ប្រការ៣០.-**

នីតិវិធីនៃការដោះស្រាយវិវាទត្រូវផ្អាក ឬបង្អង់ ពេលមានហេតុណាមួយ ដូចខាងក្រោម៖

១- ការដកខ្លួន ការផ្លាស់ប្តូរ ការបាត់បង់សមត្ថភាព ឬមរណភាព របស់អ្នកដោះស្រាយវិវាទ

២- ការបាត់បង់សមត្ថភាព ឬមរណភាពរបស់ភាគីវិវាទ

៣- ការរំលត់នីតិបុគ្គលដែលជាភាគីវិវាទ ដោយការរួមបញ្ចូលគ្នា

៤- ករណីប្រធានសក្តិ

៥- ករណីផ្សេងទៀត ដែលអ្នកដោះស្រាយវិវាទយល់ថាប៉ះពាល់ដល់ដំណើរការដោះស្រាយវិវាទ។

រយៈពេលនៃការដោះស្រាយវិវាទ ដូចមានចែងក្នុងប្រការ៣២ នៃប្រកាសនេះ ត្រូវផ្អាក ឬបង្អង់រហូតដល់ពេលដែលនីតិវិធីនៃការដោះស្រាយវិវាទត្រូវចាប់ផ្តើមឡើងវិញ។

**ប្រការ៣១.-**

ការដោះស្រាយវិវាទត្រូវបញ្ចប់ក្នុងករណី ដូចខាងក្រោម៖

១- **គ.ដ.ម.** បានចេញសេចក្តីសម្រេចបញ្ចប់វិវាទ

២- ភាគីវិវាទសះជានឹងគ្នាមុនពេលអ្នកដោះស្រាយវិវាទចេញសេចក្តីសម្រេចបញ្ចប់វិវាទ

៣- ភាគីវិវាទព្រមព្រៀងគ្នាដកខ្លួនចេញពីការដោះស្រាយវិវាទ

៤- ភាគីវិវាទបំពានធ្ងន់ធ្ងរចំពោះបញ្ញត្តិដែលមានចែងក្នុងប្រកាសនេះ

៥- ភាគីវិវាទបានទទួលមរណភាព ឬបានរំលត់នីតិបុគ្គលហើយគ្មានអ្នកទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង។

បន្ទាប់ពីទទួលបានចំណាត់ការលើវិវាទរបស់អ្នកដោះស្រាយវិវាទ **គ.ដ.ម.** ត្រូវកោះប្រជុំ **គ.ដ.ម.** ដើម្បីពិនិត្យ និងសម្រេចលើវិវាទ។

ក្រោយពីការបញ្ចប់នីតិវិធីដោះស្រាយវិវាទ **គ.ដ.ម.** ត្រូវចេញសេចក្តីសម្រេចបញ្ចប់វិវាទ។ **គ.ដ.ម.** អាចស្នើសុំអនុសាសន៍ដឹកនាំរបស់អគ្គនាយកនៃ **ន.ម.ធ.** មុននឹងចេញសេចក្តីសម្រេច។

**ប្រការ៣២.-**

**គ.ដ.ម.** ត្រូវបញ្ចប់ការដោះស្រាយវិវាទក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការដោយគិតចាប់ពីថ្ងៃដែលអ្នកដោះស្រាយវិវាទត្រូវបានចាត់តាំង លើកលែងករណីដូចខាងក្រោម៖

១- ការដកខ្លួន ការផ្លាស់ប្តូរ ការបាត់បង់សមត្ថភាព ឬមរណភាព របស់អ្នកដោះស្រាយវិវាទ
២- ការបាត់បង់សមត្ថភាព ឬមរណភាពរបស់ភាគីវិវាទ
៣- ការរំលត់នីតិបុគ្គលដែលជាភាគីវិវាទ ដោយការរួមបញ្ចូលគ្នា
៤- ករណីប្រធានសក្តិ
៥- ករណីផ្សេងទៀត ដែលអ្នកផ្សះផ្សាយល់ថាប៉ះពាល់ដល់ដំណើរការដោះស្រាយវិវាទ
៦- មានការសម្រេចរបស់ **គ.ដ.ម.** តាមការស្នើសុំពន្យារពេលរបស់អ្នកដោះស្រាយវិវាទ ឬការស្នើសុំពន្យារពេលតាមការព្រមព្រៀងរបស់ភាគីវិវាទ។

**ប្រការ៣៣.-**

**គ.ដ.ម.** ត្រូវចេញសេចក្តីសម្រេច ដោយផ្អែកតាម៖
១- ការស្រុះស្រួលរបស់ភាគីវិវាទ
២- ភាពសមហេតុផល សមធម៌ ឬឧត្តមានុវត្តន៍ក្នុងវិស័យបរធនបាលកិច្ច
៣- ច្បាប់ និងបទប្បញ្ញត្តិជាធរមានដែលយល់ថាអាចអនុវត្តបានចំពោះកម្មវត្ថុនៃវិវាទ។

## ជំពូកទី៦
## បទប្បញ្ញត្តិរួម

**ប្រការ៣៤.-**

ការិយាល័យដោះស្រាយពាក្យបណ្តឹង ជាសេនាធិការឱ្យ **ន.ម.ធ.** និងជាលេខាធិការដ្ឋាននៃ **គ.ដ.ម.** ត្រូវរក្សាទុករបាយការណ៍ស្តីពីការដោះស្រាយវិវាទ និងពាក្យបណ្តឹង ព្រមទាំងឯកសារពាក់ព័ន្ធ និងសំណុំរឿងផ្សះផ្សានិងដោះស្រាយវិវាទទាំងអស់ ក្នុងរយៈពេល ១០ (ដប់) ឆ្នាំ ក្នុងទម្រង់ទន់ និងទម្រង់រឹង។

**ប្រការ៣៥.-**

ភាគីបរធនបាលកិច្ច ប្រតិបត្តិករបរធនបាលកិច្ច អ្នកផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងបុគ្គលចូលរួមដទៃទៀតក្នុងវិស័យបរធនបាលកិច្ច ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី/ការទទួលស្គាល់ពី **ន.ម.ធ.** ត្រូវមានខចែងអំពីការដោះស្រាយវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការបរធនបាលកិច្ច នៅក្នុងលិខិតបរធន-បាលកិច្ច។

**ប្រការ៣៦.-**

ត្រូវចាត់ទុកថាភាគីវិវាទទទួលបានលិខិតអញ្ជើញ លិខិតជូនដំណឹង កិច្ចព្រមព្រៀងសះជា កំណត់ហេតុមិនសះជា សេចក្តីសម្រេច ឬឯកសារពាក់ព័ន្ធផ្សេងៗក្នុងដំណើរការផ្សះផ្សា និងដោះស្រាយវិវាទ ក្នុងករណីបានប្រគល់លិខិតនោះឱ្យភាគីវិវាទ ឬអ្នកតំណាង ឬប្រគល់ដល់កន្លែងធ្វើពាណិជ្ជកម្ម ឬទីលំនៅ ឬអាសយដ្ឋានសារអេឡិចត្រូនិក ឬអាសយដ្ឋានប្រៃសណីយ៍។

**ប្រការ៣៧.-**

អ្នកផ្សះផ្សា អ្នកដោះស្រាយវិវាទ ភាគីវិវាទ អ្នកបកប្រែភាសា អ្នកជំនាញ មេធាវី និងបុគ្គលពាក់ព័ន្ធផ្សេងទៀតក្នុងដំណើរការផ្សះផ្សា ឬដោះស្រាយវិវាទ ត្រូវរក្សាការសម្ងាត់នូវរាល់ព័ត៌មាន ការឆ្លើយឆ្លងសារ


Ch.ßL

អេឡិចត្រូនិក រឿងរ៉ាវដែលបានពិភាក្សា សេចក្តីស្នើ កំណត់ហេតុ និងឯកសារពាក់ព័ន្ធផ្សេងទៀត ដោយមិនត្រូវបើកបង្ហាញ ឬ បកស្រាយ ឬយកទៅផ្សព្វផ្សាយជាសាធារណៈ ទោះធ្វើឡើងតាមរយៈការនិយាយក្តី ឬការសម្តែងក្តី ឬក្រោមរូបភាពណាមួយក៏ដោយ លើកលែងតែករណី ដូចខាងក្រោម៖

១- មានការយល់ព្រមពីភាគីវិវាទទាំងអស់ ដោយមានបញ្ជាក់ពីបុគ្គលដែលមានសិទ្ធិទទួលព័ត៌មានសម្ងាត់នោះ

២- តម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន

៣- ព័ត៌មាន ឬឯកសារទាំងនោះ មិនត្រូវបានបង្ហាញអត្តសញ្ញាណរបស់ភាគីវិវាទទាំងអស់

៤- តាមការកំណត់របស់ **ន.ម.ឆ.** ឬតុលាការមានសមត្ថកិច្ច

៥- ព័ត៌មានដែលចាត់ទុកជាព័ត៌មានសាធារណៈ។

**ប្រការ៣៨.-**

សមាជិក **ក.ជ.ម.** អ្នកផ្សះផ្សា អ្នកដោះស្រាយវិវាទ និងមន្ត្រីពាក់ព័ន្ធ ត្រូវរួចផុតពីការទទួលខុសត្រូវទាំងអស់នៅក្នុងការអនុវត្តតួនាទី ភារកិច្ច និងសិទ្ធិអំណាច ដោយសុចរិត ផ្អែកតាមភាពស្មោះត្រង់ ដូចមានចែងក្នុងប្រកាសនេះ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៧
## កម្រៃសេវា និងប្រាក់តម្កល់

**ប្រការ៣៩.-**

មុនចាប់ផ្តើមដំណើរការផ្សះផ្សា ឬដោះស្រាយវិវាទ ភាគីវិវាទត្រូវចុះកិច្ចព្រមព្រៀងផ្សះផ្សា ឬដោះស្រាយវិវាទ និងបង់កម្រៃសេវារដ្ឋបាល សេវាសម្រាប់អ្នកផ្សះផ្សា ឬអ្នកដោះស្រាយវិវាទ និងដាក់ប្រាក់តម្កល់សម្រាប់ទូទាត់សោហ៊ុយចំណាយផ្សេងៗនៅក្នុងដំណើរការផ្សះផ្សា ឬដោះស្រាយវិវាទ ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

កម្រៃសេវារដ្ឋបាល និងកម្រៃសេវាសម្រាប់អ្នកផ្សះផ្សាឬអ្នកដោះស្រាយវិវាទ និងប្រាក់តម្កល់ ត្រូវបង់ដោយភាគីវិវាទក្នុងចំណែកស្មើៗគ្នា លើកលែងតែមានការព្រមព្រៀងផ្សេងទៀតដោយភាគីវិវាទ។

ករណីភាគីវិវាទដែលប្តឹងទាមទារ មិនបានចូលរួមក្នុងដំណើរការផ្សះផ្សា ឬដោះស្រាយវិវាទ តាមប្រការ១៨ ឬប្រការ២៨ នៃប្រកាសនេះ ភាគីវិវាទដែលប្តឹងទាមទារនោះត្រូវទទួលបន្ទុករាល់ការចំណាយទាំងអស់ក្នុងកិច្ច-ដំណើរការផ្សះផ្សា ឬដោះស្រាយវិវាទ។

ករណីមានការព្រមព្រៀងគ្នាដោយភាគីវិវាទ លើការជ្រើសរើសអ្នកផ្សះផ្សា ឬអ្នកដោះស្រាយវិវាទដទៃក្រៅពី **ក.ជ.ម.** ភាគីវិវាទត្រូវបង់កម្រៃសេវាសម្រាប់អ្នកផ្សះផ្សា ឬអ្នកដោះស្រាយវិវាទនោះ ក្នុងចំណែកស្មើៗគ្នា ឬតាមការព្រមព្រៀងផ្សេងទៀតដោយភាគីវិវាទ។

ថ្លៃពាក្យស្នើសុំផ្សះផ្សា និងដោះស្រាយវិវាទ និងកម្រៃរដ្ឋបាលដែលបង់មក **ន.ម.ឆ.** មិនអាចដកវិញបានឡើយ ទោះបីជាការស្នើសុំផ្សះផ្សា និងដោះស្រាយវិវាទ ត្រូវបានបដិសេធ។

**ប្រការ៤០.-**

ភាគីវិវាទត្រូវដាក់ប្រាក់តម្កល់រៀងខ្លួននៅ **ន.ម.ឆ.** ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល សម្រាប់ធានាការទូទាត់ចំពោះសោហ៊ុយចំណាយផ្សេងៗ និងចំណាយឥតព្រាងទុកនៅក្នុងដំណើរការផ្សះផ្សា ឬដោះស្រាយវិវាទ។

ករណីប្រាក់តម្កល់សម្រាប់ការផ្សះផ្សា ឬការដោះស្រាយវិវាទ មិនអាចទូទាត់សោហ៊ុយចំណាយបាន ភាគីវិវាទត្រូវទូទាត់សោហ៊ុយចំណាយបន្ថែមតាមជាក់ស្តែង។

ករណីវិវាទត្រូវបានបញ្ចប់ក្នុងដំណើរការផ្សះផ្សា ឬដោះស្រាយវិវាទ ប្រាក់តម្កល់ដែលនៅសល់ក្រោយការទូទាត់ចំណាយ ត្រូវប្រគល់ជូនភាគីវិវាទ ក្នុងរយៈពេលយ៉ាងយូរ ១៤ (ដប់បួន) ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃភាគីវិវាទទទួលបានកិច្ចព្រមព្រៀងសះជា ឬសេចក្តីសម្រេច។

**ប្រការ៤១**.-

សោហ៊ុយចំណាយចំពោះអ្នកបកប្រែភាសា និងអ្នកជំនាញ ជាបន្ទុករបស់ភាគីវិវាទដែលស្នើសុំ ឬជាបន្ទុករបស់ភាគីវិវាទក្នុងចំណែកស្មើៗគ្នា ក្នុងករណីអ្នកផ្សះផ្សា ឬអ្នកដោះស្រាយវិវាទតម្រូវឱ្យមាន លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយភាគីវិវាទ។

## ជំពូកទី៨
## ទណ្ឌកម្ម

**ប្រការ៤២**.-

បរធនបាល ប្រតិបត្តិករបរធនបាល និងបុគ្គលផ្សេងទៀតដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី/ការទទួលស្គាល់ពី **ន.ម.ធ**. ដែលមិនអនុវត្តតាមសេចក្តីសម្រេចរបស់ **ក.ជ.ម**. ឬកាតព្វកិច្ចដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលរងវិធានការរដ្ឋបាលពីមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដូចខាងក្រោម៖

-ការព្រមាន

-ការដឹកនាំកែតម្រង់

-ការដាក់កំហិតលើអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី/ការទទួលស្គាល់

-ការដាក់កំហិតលើការចាត់ចែង និងគ្រប់គ្រង និង/ឬការថែរក្សាទ្រព្យសម្បត្តិបរធនបាលកិច្ច

-ការព្យួរ ឬបណ្តេញចេញពីមុខតំណែងអភិបាល បុគ្គលិកជាន់ខ្ពស់ និង/ឬបុគ្គលប្រព្រឹត្តល្មើស

-ការដកហូតអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី/ការទទួលស្គាល់។

**ប្រការ៤៣**.-

បែបបទ និងនីតិវិធីនៃការចាត់វិធានការរដ្ឋបាល ដូចមានចែងក្នុងជំពូកនេះត្រូវអនុលោមតាមប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាល និងពិន័យអន្តរការណ៍។

បុគ្គលដែលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដូចមានចែងក្នុងជំពូកនេះ អាចប្តឹងតវ៉ាតាមនីតិវិធីស្របតាមច្បាប់ស្តីពីបរធនបាលកិច្ច។

**ប្រការ៤៤**.-

វិធានការរដ្ឋបាល ដូចមានចែងក្នុងជំពូកនេះមិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**ប្រការ៤៥**.-

**ន.ប.ធ.** អាចចេញគោលការណ៍ណែនាំ ស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ។

**ប្រការ៤៦**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤៧**.-

អគ្គលេខាធិការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១០កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ.
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៤៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ ០១០ ស.ណ.ហ.ប្រ.ក**
**ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០២៦**
**ស្តីពី**
**កម្រៃសេវារដ្ឋបាល និងកម្រៃសេវា**
**សម្រាប់អ្នកផ្សះផ្សា និងអ្នកដោះស្រាយវិវាទ**

## ១. កម្រៃសេវារដ្ឋបាលសម្រាប់ការផ្សះផ្សា ឬការដោះស្រាយវិវាទ

ភាគីវិវាទត្រូវបង់កម្រៃសេវារដ្ឋបាលតាមកម្រិតនៃសេវាដែលត្រូវបានកំណត់ ដូចខាងក្រោម៖

| តម្លៃដែលជាកម្មវត្ថុនៃបណ្តឹង (គិតជាប្រាក់រៀល) | | កម្រិតនៃកម្រៃសេវា (គិតជាប្រាក់រៀល) | | | | |
|---|---|---|---|---|---|---|
| តិចជាង | ២០០.០០០.០០០ | ៣.០០០.០០០ | | | | |
| ចាប់ពី | ២០០.០០០.០០១ ដល់ ៤០០.០០០.០០០ | ៦.០០០.០០០ | + | ០,៨០% | នៃចំនួនដែលលើសពី | ២០០.០០០.០០០ |
| ចាប់ពី | ៤០០.០០០.០០១ ដល់ ២.០០០.០០០.០០០ | ៧.៦០០.០០០ | + | ០,៧០% | នៃចំនួនដែលលើសពី | ៤០០.០០០.០០០ |
| ចាប់ពី | ២.០០០.០០០.០០១ ដល់ ៤.០០០.០០០.០០០ | ១៨.៨០០.០០០ | + | ០,៥០% | នៃចំនួនដែលលើសពី | ២.០០០.០០០.០០០ |
| ចាប់ពី | ៤.០០០.០០០.០០១ ដល់ ១២.០០០.០០០.០០០ | ២៨.៨០០.០០០ | + | ០,៥០% | នៃចំនួនដែលលើសពី | ៤.០០០.០០០.០០០ |
| ចាប់ពី | ១២.០០០.០០០.០០១ ដល់ ២០.០០០.០០០.០០០ | ៤៤.៨០០.០០០ | + | ០,១២% | នៃចំនួនដែលលើសពី | ១២.០០០.០០០.០០០ |
| ចាប់ពី | ២០.០០០.០០០.០០១ ដល់ ៤០.០០០.០០០.០០០ | ៥៤.៤០០.០០០ | + | ០,០៨% | នៃចំនួនដែលលើសពី | ២០.០០០.០០០.០០០ |
| ចាប់ពី | ៤០.០០០.០០០.០០១ ដល់ ២០០.០០០.០០០.០០០ | ៧០.៤០០.០០០ | + | ០,០៤% | នៃចំនួនដែលលើសពី | ៤០.០០០.០០០.០០០ |
| លើសពី | ២០០.០០០.០០០.០០០ | ១៣៤.៤០០.០០០ | | | | |

## ២. កម្រៃសេវាសម្រាប់អ្នកផ្សះផ្សា ឬអ្នកដោះស្រាយវិវាទ

កម្រៃសេវាសម្រាប់អ្នកផ្សះផ្សា ឬអ្នកដោះស្រាយវិវាទ ត្រូវកំណត់តាមកម្រិតអត្រាជាភាគរយដែលប្រែប្រួលទៅតាមតម្លៃនៃកម្មវត្ថុនៃបណ្តឹង និងកំណត់ស្របតាមតារាងខាងក្រោម៖

| តម្លៃដែលជាកម្មវត្ថុនៃបណ្តឹង (គិតជាប្រាក់រៀល) | | កម្រិតនៃកម្រៃសេវា (គិតជាប្រាក់រៀល) | | | | |
|---|---|---|---|---|---|---|
| តិចជាង | ២០០.០០០.០០០ | ៤.០០០.០០០ | | | | |
| ចាប់ពី | ២០០.០០០.០០១ ដល់ ៤០០.០០០.០០០ | ១១.០០០.០០០ | + | ២% | នៃចំនួនដែលលើសពី | ២០០.០០០.០០០ |
| ចាប់ពី | ៤០០.០០០.០០១ ដល់ ២.០០០.០០០.០០០ | ១៥.០០០.០០០ | + | ១,៧០% | នៃចំនួនដែលលើសពី | ៤០០.០០០.០០០ |
| ចាប់ពី | ២.០០០.០០០.០០១ ដល់ ៤.០០០.០០០.០០០ | ៤២.២០០.០០០ | + | ១,៥០% | នៃចំនួនដែលលើសពី | ២.០០០.០០០.០០០ |
| ចាប់ពី | ៤.០០០.០០០.០០១ ដល់ ១២.០០០.០០០.០០០ | ៧២.២០០.០០០ | + | ០,៧៥% | នៃចំនួនដែលលើសពី | ៤.០០០.០០០.០០០ |
| ចាប់ពី | ១២.០០០.០០០.០០១ ដល់ ២០.០០០.០០០.០០០ | ១៣២.២០០.០០០ | + | ០,៥០% | នៃចំនួនដែលលើសពី | ១២.០០០.០០០.០០០ |

| | | | | | | |
|---|---|---|---|---|---|---|
| ចាប់ពី | ២០.០០០.០០០.០០១ ដល់ ៤០.០០០.០០០.០០០ | ១៧២.២០០.០០០ | | ០,៣០% | | ២០.០០០.០០០.០០០ |
| ចាប់ពី | ៤០.០០០.០០០.០០១ ដល់ ២០០.០០០.០០០.០០០ | ២៣២.២០០.០០០ | | ០,១៥% | | ៤០.០០០.០០០.០០០ |
| លើសពី | ២០០.០០០.០០០.០០០ | ៤៧២.២០០.០០០ | | ០,០៧៥% | | ២០០.០០០.០០០.០០០ |

ការគណនាអត្រានៃកម្រៃសេវាត្រូវបានគិតតាមរបៀបដូចខាងក្រោម៖

កម្រៃសេវាដែលទទួលបាន = កម្រិតនៃកម្រៃសេវាគោល + (ចំនួនលើសនៃតម្លៃកម្មវត្ថុបណ្តឹង x ភាគរយនៃកម្រៃសេវា)

ឧទាហរណ៍ទី១៖ ករណីដែលកម្មវត្ថុនៃបណ្តឹងចំនួន ២៥០.០០០.០០០ រៀល

កម្រៃសេវាដែលទទួលបាន = ១១.០០០.០០០ + (៥០.០០០.០០០ x ២%)

= ២១.០០០.០០០ រៀល

ឧទាហរណ៍ទី២៖ ករណីដែលកម្មវត្ថុនៃបណ្តឹងចំនួន ៣៤.០០០.០០០.០០០ រៀល

កម្រៃសេវាដែលទទួលបាន = ១៧២.២០០.០០០ + (១៤.០០០.០០០.០០០ x ០,៣០%)

= ២១៤.២០០.០០០ រៀល